## រាជរដ្ឋាភិបាលកម្ពុជា

# ផែនការសកម្មភាព ២០១៦-២០១៨

## នៃ

## គោលនយោបាយជាតិប្រជាជន ២០១៦-២០៣០

**បន្តលើកកម្ពស់គុណភាពជីវិត និង សុខុមាលភាពរបស់ប្រជាជន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

# អារម្ភកថា

រាជរដ្ឋាភិបាលកម្ពុជា ប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការអនុវត្ត គោលនយោបាយជាតិប្រជាជន ២០១៦-២០៣០ សំដៅលើកកម្ពស់គុណភាពជីវិតរបស់ប្រជាជនកម្ពុជា។ ក្នុងស្មារតីនេះ ផែនការសកម្មភាពបីឆ្នាំ ២០១៦-២០១៨ ដែលជាផែនការសកម្មភាពលើកទីមួយ ត្រូវបានរៀបចំឡើងដើម្បីផ្តល់ការតម្រង់ទិសដល់ការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវ គោលនយោបាយជាតិប្រជាជន។

ការអនុវត្តគោលនយោបាយជាតិប្រជាជន តាមរយៈផែនការសកម្មភាពមួយដែលបានរៀបចំឡើងដោយមានការសម្របសម្រួលបានល្អ គឺជាការរួមចំណែកដ៏សំខាន់ដល់ការអភិវឌ្ឍជាតិ រយៈពេលវែង ជាពិសេស ដល់ការអភិវឌ្ឍមូលធនមនុស្សប្រកបដោយនិរន្តរភាព នៅក្នុងបរិការណ៍នៃការអភិវឌ្ឍមួយ ដែលមានការប្រែប្រួលយ៉ាងលឿន ទាំងនៅក្នុងកម្រិតជាតិ ទាំងនៅក្នុងកម្រិតតំបន់ឬកម្រិតសាកល។

ផែនការសកម្មភាព ២០១៦-២០១៨ នៃគោលនយោបាយជាតិប្រជាជន ត្រូវបានរៀបចំឡើងដើម្បីជួយតម្រង់ទិសដល់កិច្ចសម្របសម្រួល និងកិច្ចសហការរបស់អ្នកមានចំណែកពាក់ព័ន្ធសំខាន់ៗ រួមមាន វិស័យសាធារណៈ វិស័យឯកជន ដៃគូអភិវឌ្ឍន៍ និង អង្គការសង្គមស៊ីវិល នៅក្នុងការអនុវត្តរួមគ្នានូវផែនការសកម្មភាពនេះ ដើម្បីលើកកម្ពស់គុណភាពជីវិតរបស់ប្រជាជនកម្ពុជា តាមរយៈ ការធ្វើឲ្យមានការកើនឡើងនៃចំណូលគ្រួសារ ការអភិវឌ្ឍទីក្រុងនិងជនបទឬតាមតំបន់ដោយមានផែនការច្បាស់លាស់ ការអភិរក្សបរិស្ថាន និងការលើកកម្ពស់កម្មវិធីបណ្តាញសុវត្ថិភាពសង្គម និង ដើម្បីធ្វើឲ្យប្រជាជនកម្ពុជា ទទួលបានការអប់រំល្អ មានមុខវិជ្ជាជំនាញជាក់លាក់ មានសុខភាពមាំមួន និងមានឱកាសសម្រាប់ការងារ។

ផែនការសកម្មភាព ២០១៦-២០១៨ ផ្តោតលើការអនុវត្ត កម្មវិធី អនុកម្មវិធី គម្រោង និងសកម្មភាពទាំងឡាយ ដើម្បីឆ្លើយតបទៅនឹងការតម្រង់ទិសជាលក្ខណៈគោលនយោបាយ និងកម្មវិធីដែលត្រូវបានកំណត់ ដោយផ្អែកលើការវិភាគអំពីនិន្នាការនិងរចនាសម្ព័ន្ធប្រជាសាស្ត្រ ជាពិសេសអំពីឌីណាមិកប្រជាសាស្ត្រ ក្នុងនោះមាន អត្រាកំណើន រចនាសម្ព័ន្ធអាយុ អត្រាផ្តល់កំណើតអត្រាមរណភាព និងទេសន្តរប្រវេសន៍ ដែលជះឥទ្ធិពលលើរាល់ទិដ្ឋភាពនៃការអភិវឌ្ឍមនុស្សសង្គម និងសេដ្ឋកិច្ច និង ចីរភាពបរិស្ថាន ក៏ដូចជា សុខភាពបន្តពូជ ការធ្វើផែនការគ្រួសារតាមការ

ស្ម័គ្រចិត្ត និង ការផ្តល់ភាពអង់អាចដល់ស្ត្រី ដែលជះឥទ្ធិពលយ៉ាងខ្លាំងលើនិន្នាការប្រជាសាស្ត្រ។ ក្នុងស្មារតីនេះ ចំណងទាក់ទងទៅវិញទៅមករវាង ការលើកកម្ពស់គុណភាពនៃជីវិត ការអភិវឌ្ឍមនុស្ស និង ឌីណាមិកប្រជាសាស្ត្រ ដែលជាចំណុចគន្លឹះនៅក្នុងដំណើរការនៃការលុបបំបាត់ភាពក្រីក្រនៅកម្ពុជា គឺជាក្របខ័ណ្ឌទស្សនៈរួម សម្រាប់ការរៀបចំផែនការសកម្មភាពនេះ។ ជាមួយគ្នានេះ ការយល់ដឹងពីបម្រែបម្រួលប្រជាសាស្ត្រនិងផលប៉ះពាល់របស់វា មានសារៈសំខាន់សម្រាប់ការអនុវត្តផែនការសកម្មភាពប្រកបដោយប្រសិទ្ធភាព ទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ក្រោមជាតិ។

ក្នុងន័យនេះ រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ ភាពចាំបាច់ក្នុងការផ្តល់ការគាំទ្រនិងការបង្កើតឲ្យមានបរិស្ថានកម្រិតគោលនយោបាយនិងកម្រិតកម្មវិធីដែលអំណោយផល សម្រាប់ការអនុវត្តផែនការសកម្មភាព និង ភាពចាំបាច់ក្នុងការធានាឲ្យមានកិច្ចសម្របសម្រួលប្រកបដោយប្រសិទ្ធភាពនៅក្នុងដំណើរការនៃការអនុវត្តគោលនយោបាយ រវាងអ្នកមានចំណែកពាក់ព័ន្ធទាំងឡាយ ដែលមានភារៈកិច្ចក្នុងការដោះស្រាយបញ្ហាប្រជាជននិងការអភិវឌ្ឍ។ ក្នុងន័យនេះ ក្រសួងផែនការមានតួនាទីជាស្ថាប័នសម្របសម្រួលរួម ក្នុងការរៀបចំផែនការសកម្មភាព និងការតាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្ត ទៅតាមវដ្តបីឆ្នាំនៃផែនការនេះ។

ដោយហេតុថា បញ្ហាប្រជាជនមានលក្ខណៈអន្តរវិស័យ ការអនុវត្តប្រកបដោយជោគជ័យនូវ **ផែនការសកម្មភាព ២០១៦-២០១៨ នៃគោលនយោបាយជាតិប្រជាជន** ទាមទារឲ្យមានកិច្ចខិតខំប្រឹងប្រែងរួមគ្នារវាង អ្នកមានចំណែកពាក់ព័ន្ធទាំងអស់ រួមមាន វិស័យសាធារណៈ វិស័យឯកជន ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និង ប្រជាជនកម្ពុជា ទាំងមូល។

ខ្ញុំមានការជឿជាក់យ៉ាងមុតមាំថា ការអនុវត្ត**ផែនការសកម្មភាព ២០១៦-២០១៨ នៃគោលនយោបាយជាតិប្រជាជន** នឹងរួមចំណែកយ៉ាងច្រើនដល់ ការលើកកម្ពស់គុណភាពជីវិត និង កម្រិតជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា។

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៧

**ហ៊ុន សែន**

# បុព្វកថា

**គោលនយោបាយជាតិប្រជាជន ២០១៦-២០៣០** ដែលទទួលបានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី៤ ខែមីនា ឆ្នាំ២០១៦ ត្រូវបានប្រកាសផ្សព្វផ្សាយដាក់ឲ្យប្រើប្រាស់ជាផ្លូវការ នាថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១៦ ក្រោមអធិបតីដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** នៅវិមានសន្តិភាព។

**គោលនយោបាយជាតិប្រជាជន ២០១៦-២០៣០** បានកំណត់នូវវិស័យអាទិភាពបួនៈ (i) ការអភិវឌ្ឍនិងការពង្រីកហេដ្ឋារចនាសម្ព័ន្ធ (ii) ការគ្រប់គ្រងការធ្វើទេសន្តរប្រវេសន៍និងនគរូបនីយកម្ម (iii) ការពង្រីកវិស័យកសិកម្មនិងសកម្មភាពពាក់ព័ន្ធ និង (iv) ការវិនិយោគលើវិស័យសង្គមកិច្ចនិងការអភិវឌ្ឍមូលធនមនុស្ស។ ដើម្បីជាការចង្អុលបង្ហាញដល់ការអនុវត្តជាក់ស្តែង **គោលនយោបាយជាតិប្រជាជន ២០១៦-២០៣០** បានកំណត់ការតម្រង់ទិសដែលមានលក្ខណៈគោលនយោបាយនិងកម្មវិធី សម្រាប់អាទិភាពនិមួយៗ។ ការតម្រង់ទិសគោលនយោបាយនិងកម្មវិធីនេះ ត្រូវបានប្រើប្រាស់ធ្វើជាមូលដ្ឋាន សម្រាប់ការរៀបចំ **ផែនការសកម្មភាពដែលមានរយៈពេលបីឆ្នាំ**។ ក្រសួង-ស្ថាប័ននីមួយៗបានតម្រឹមតម្រង់កម្មវិធី អនុកម្មវិធី និងគម្រោងរបស់ខ្លួន ទៅនឹងការតម្រង់ទិសគោលនយោបាយនិងកម្មវិធីទាំងឡាយ ដែលបានកំណត់នៅក្នុង **គោលនយោបាយជាតិប្រជាជន ២០១៦-២០៣០**។

**ផែនការសកម្មភាពរបស់គោលនយោបាយជាតិប្រជាជន ២០១៦-២០៣០** នឹងត្រូវអនុវត្តជាប្រាំដំណាក់កាល ហើយ នេះគឺជាផែនការសកម្មភាពទី១ សម្រាប់ដំណាក់កាល ២០១៦-២០១៨ ដែលនឹងត្រូវបន្តដោយ ផែនការសកម្មភាពទី២ (២០១៩-២០២១), ទី៣ (២០២២-២០២៤), ទី៤ (២០២៥-២០២៧) និង ទី៥ (២០២៨-២០៣០)។ **ផែនការសកម្មភាព ២០១៦-២០១៨** នេះ គឺជាលទ្ធផលនៃការពិគ្រោះយោបល់រវាងអ្នកមានចំណែកពាក់ព័ន្ធទាំងអស់ ហើយ ត្រូវប្រើប្រាស់ជាឧបករណ៍ដ៏សំខាន់ សម្រាប់ការតាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្ត**គោលនយោបាយជាតិប្រជាជន ២០១៦-២០៣០**។ កម្មវិធី អនុកម្មវិធី គម្រោង និងសកម្មភាពទាំងឡាយ ដែលត្រូវដាក់បញ្ចូលទៅក្នុងផែនការសកម្មភាពតាមដំណាក់កាលនីមួយៗ អាចមានក្របខ័ណ្ឌពេលវេលាមួយ ដែលស្ថិតនៅក្នុងក្របខ័ណ្ឌពេលវេលារបស់**គោលនយោបាយជាតិប្រជាជន**។

ក្រសួងផែនការ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ក្រសួង-ស្ថាប័នទាំងអស់ដែលបានផ្តល់កិច្ចសហការយ៉ាងល្អ ក្នុងការរៀបចំផែនការសកម្មភាពទី១ សម្រាប់ដំណាក់កាល ២០១៦-២០១៨ ដែលអាចឲ្យយើងសម្រេចបានឯកសារមួយ ជាមូលដ្ឋានសម្រាប់ការអនុវត្តជាក់ស្តែងនូវ កម្មវិធី អនុកម្មវិធី គម្រោង និងសកម្មភាពទាំងឡាយ ដែលបានដាក់បញ្ចូលក្នុងតារាងម៉ាទ្រីសនៃផែនការសកម្មភាពនេះ។ ក្រសួងផែនការមានជំនឿយ៉ាងមុតមាំថា ក្នុងស្មារតីនៃការរួមចំណែកក្នុងការបន្តលើកកម្ពស់គុណភាពជីវិតនិងសុខុមាលភាពរបស់ប្រជាជនកម្ពុជា ក្រសួង-ស្ថាប័នជំនាញនិងអ្នកមានចំណែកពាក់ព័ន្ធទាំងអស់ នឹងសហការគ្នាយ៉ាងជិតស្និទ្ធក្នុងការធានាឲ្យមានយន្តការសម្របសម្រួលជាលក្ខណៈ

អន្តរវិស័យប្រកបដោយប្រសិទ្ធភាព និង ការធ្វើហិរញ្ញប្បទានសមស្របនិងទាន់ពេលវេលា ដើម្បីសម្រេចបានជោគជ័យក្នុងការអនុវត្តផែនការសកម្មភាពនេះ។

អគ្គលេខាធិការដ្ឋានប្រជាជននិងការអភិវឌ្ឍនៃក្រសួងផែនការ នឹងសម្របសម្រួលការតាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តផែនការសកម្មភាពនេះ នៅគ្រប់ដំណាក់កាលនីមួយៗ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ២០១៦

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងផែនការ**

**ឆាយ ថន**

# មាតិកា


មាតិកា ........ i

១- សេចក្តីផ្តើម ........ ១

២- អភិក្រមសម្រាប់ការអនុវត្តគោលនយោបាយជាតិប្រជាជន ២០១៦-២០៣០ តាមរយៈផែនការសកម្មភាព ២០១៦-២០១៨ ........ ២

៣- ម៉ាទ្រីសនៃផែនការសកម្មភាព ........ ៣

៤- ប្រភពហិរញ្ញប្បទាននិងចំណាយប៉ាន់ស្មាន ........ ១០១

៥- ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ ........ ១០៣

៦- សេចក្តីសន្និដ្ឋាន ........ ១០៤

## ១- សេចក្ដីផ្ដើម

គោលនយោបាយជាតិប្រជាជន ២០១៦-២០៣០ ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី៤ ខែមិនា ឆ្នាំ២០១៦ និងដែលបានប្រកាសផ្សព្វផ្សាយដាក់ឲ្យប្រើប្រាស់ជាផ្លូវការនាថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១៦ ដោយប្រមុខរាជរដ្ឋាភិបាលកម្ពុជា ជាផែនទីតម្រង់ផ្លូវមួយដែលមានរយៈពេលវែង មានលក្ខណៈគ្រប់ជ្រុងជ្រោយ គ្របដណ្ដប់លើគ្រប់វិស័យ និងប្រកបដោយបរិយាប័ន្ន ហើយ ត្រូវបានរៀបចំឡើង ដោយផ្អែកលើទិដ្ឋភាពជាក់ស្ដែងនៃដំណើរអភិវឌ្ឍសង្គមកិច្ច-សេដ្ឋកិច្ចជាតិ បម្រែបម្រួលប្រជាសាស្ត្រ និងផលប៉ះពាល់នៃបម្រែបម្រួលប្រជាសាស្ត្រ ទៅលើការអភិវឌ្ឍប្រកបដោយចីរភាព។ គោលនយោបាយនេះ បានបន្ស៊ីចក្ខុវិស័យរបស់ខ្លួន ព្រមទាំងការតម្រង់ទិសគោលនយោបាយនិងកម្មវិធី ទៅនឹងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ ព្រមទាំងគោលនយោបាយនិងយុទ្ធសាស្ត្រជាតិជាច្រើនទៀតរបស់រាជរដ្ឋាភិបាល និង អនុលោមទៅតាមសន្និសីទអន្តរជាតិនានា ដែលកម្ពុជាជាប្រទេសហត្ថលេខី ដូចជា សន្និសីទអន្តរជាតិស្ដីពីប្រជាជននិងការអភិវឌ្ឍឆ្នាំ១៩៩៤ សេចក្ដីប្រកាសសហស្សវត្សរ៍ឆ្នាំ២០០០ សេចក្ដីប្រកាសនៃការប្ដេជ្ញាចិត្តចំពោះមេរោគហ៊ីវ/ជំងឺអេដស៍ អនុសញ្ញាសហប្រជាជាតិស្ដីពីសិទ្ធិកុមារ អនុសញ្ញាស្ដីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រី និង សេចក្ដីប្រកាសសកលស្ដីពីសិទ្ធិមនុស្សជាដើម។

គោលនយោបាយនេះ រួមចំណែកក្នុងការបន្ត លើកកម្ពស់គុណភាពនៃជីវិត និងសុខុមាលភាពរបស់ប្រជាជនកម្ពុជា និង កាត់បន្ថយភាពក្រីក្រនិងផលប៉ះពាល់នៃបម្រែបម្រួលប្រជាសាស្ត្រទៅលើការអភិវឌ្ឍ តាមរយៈការជំរុញឲ្យមានការបញ្ចូលបញ្ហាប្រជាជន ទៅក្នុងផែនការអភិវឌ្ឍន៍គ្រប់វិស័យ គ្រប់កម្រិត និង នៅក្នុងក្របខ័ណ្ឌនៃការអភិវឌ្ឍជាតិនិងសាកល។ ដោយសារបញ្ហាប្រជាជនមានទំនាក់ទំនងជាមួយគ្នាទៅវិញទៅមកនិងមានចរិតអន្តរពហុវិស័យ ការអនុវត្តគោលនយោបាយនេះទាមទារឲ្យមានកិច្ចខិតខំប្រឹងប្រែងរួមគ្នាពីគ្រប់អ្នកមានចំណែកពាក់ព័ន្ធទាំងអស់ រួមមាន វិស័យសាធារណៈ វិស័យឯកជន ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងសហគមន៍។ ក្នុងន័យនេះ គោលនយោបាយជាតិប្រជាជន បានចង្អុលបង្ហាញពីភាពចាំបាច់នៃការរៀបចំផែនការសកម្មភាពលម្អិត ដែលត្រូវសម្របសម្រួលដោយអគ្គលេខាធិការប្រជាជននិងការអភិវឌ្ឍនៃក្រសួងផែនការ ដើម្បីប្រែក្លាយគោលនយោ-បាយទៅជាសកម្មភាពជាក់ស្ដែង សំដៅសម្រេចបាននូវគោលបំណង និងគោលដៅដូចមានចែងក្នុងគោលនយោបាយ។

**ផែនការសកម្មភាព ២០១៦-២០១៨** ដែលជាផែនការសកម្មភាពលើកទីមួយដើម្បីអនុវត្តគោលនយោបាយជាតិប្រជាជន ២០១៦-២០៣០ ត្រូវបានរៀបចំឡើង ដើម្បីចងក្រងសកម្មភាព កម្មវិធី អនុកម្មវិធី គម្រោង និង សកម្មភាពនានា ដែលកំពុងត្រូវបានអនុវត្ត ឬ នឹងត្រូវអនុវត្តដោយក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់។ សកម្មភាពទាំងនោះពាក់ព័ន្ធនឹងបញ្ហាឌីណាមិកប្រជាសាស្ត្រ ដូចបានរំលេច

ឡើងក្នុងវិស័យអាទិភាពទាំងបួនរបស់គោលនយោបាយជាតិប្រជាជន គឺសំដៅសម្រេចឲ្យបានស្ថានភាពប្រជាជនមួយដែលល្អប្រសើរសម្រាប់ការអភិវឌ្ឍ និងរួមចំណែកដល់ការបន្តលើកកម្ពស់ ជីវភាពរស់នៅនិងសុខុមាលភាពរបស់ប្រជាជនកម្ពុជា។ ផែនការសកម្មភាពនេះ ត្រូវបានរៀបចំឡើង ដោយផ្អែកលើយន្តការមួយដែលមានការចូលរួមយ៉ាងទូលំទូលាយ ដោយក្រសួង-ស្ថាប័នពាក់ព័ន្ធទាំង អស់ត្រូវបានផ្តល់ឱកាសតម្រឹមតម្រង់ កម្មវិធី អនុកម្មវិធី គម្រោង និងសកម្មភា របស់ខ្លួន ដែលកំពុងឬនឹងត្រូវអនុវត្ត ទៅនឹងវិស័យអាទិភាពទាំងបួនរបស់គោលនយោបាយជាតិប្រជាជន។

វិស័យអាទិភាពទាំងបួនរបស់គោលនយោបាយជាតិប្រជាជន រួមមាន៖ (i) ការពង្រីកនិងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ (ii) ការគ្រប់គ្រងការធ្វើទេសន្តរប្រវេសន៍និងនគរូបនីយកម្ម (iii) ការពង្រីកវិស័យកសិកម្មនិងសកម្មភាពពាក់ព័ន្ធ និង (iv) ការវិនិយោគលើវិស័យសង្គមកិច្ច និងការអភិវឌ្ឍមូលធនមនុស្ស។ ការតម្រង់ទិសគោលនយោបាយនិងកម្មវិធីសម្រាប់វិស័យអាទិភាពនីមួយៗ ដែលមានរៀបរាប់លម្អិតនៅក្នុងគោលនយោបាយជាតិប្រជាជន ត្រូវយកធ្វើជាមូលដ្ឋានក្នុងការកំណត់ កម្មវិធី អនុកម្មវិធី គម្រោង និងសកម្មភាព របស់ស្ថាប័នអនុវត្ត ដោយរំលេចនូវសូចនាករ និងចំណុចដៅសម្រាប់ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ។

ផែនការសកម្មភាពនេះ មានគោលបំណងសំខាន់ពីរ៖ (១) ផែនការសកម្មភាព គឺជាការប្រែក្លាយការតម្រង់ទិសគោលនយោបាយនិងកម្មវិធី ឲ្យទៅជាសកម្មភាពជាក់ស្តែង ដែលត្រូវអនុវត្តដោយក្រសួង-ស្ថាប័នពាក់ព័ន្ធ និង (២) ផែនការសកម្មភាព គឺជាឧបករណ៍សម្រាប់ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ លើលទ្ធផលនៃការអនុវត្តនូវសកម្មភាពទាំងឡាយដែលបានកំណត់ទៅតាមដំណាក់កាលនីមួយៗនៃការអនុវត្តគោលនយោបាយជាតិប្រជាជន ២០១៦-២០៣០ ។

## ២- អភិក្រមសម្រាប់ការអនុវត្តគោលនយោបាយជាតិប្រជាជន ២០១៦-២០៣០ តាមរយៈផែនការសកម្មភាព ២០១៦-២០១៨

ផែនការសកម្មភាពនេះដាក់បញ្ចូលនូវកម្មវិធី អនុកម្មវិធី គម្រោង និងសកម្មភាពទាំងឡាយ

预览已结束，完整报告链接和二维码如下：
https://www.yunbaogao.cn/report/index/report?reportId=5_19504